## តើសញ្ញាអ្វីខ្លះដែលបង្ហាញថាកូនលោកអ្នកអាចស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់នៃការប្រើអ៊ិនធ័រណិត?

- កូនលោកអ្នកចំណាយពេលប្រើអ៊ិនធ័រណិតច្រើន ជាពិសេសនៅពេលយប់។
- លោកអ្នកឃើញរូបអាសអាភាសនៅក្នុងកុំព្យូទ័ររបស់កូនលោកអ្នក។
- កូនលោកអ្នកទទួលទូរស័ព្ទពីបុរសដែលលោកអ្នកមិនស្គាល់ ឬទូរស័ព្ទទៅគេ ជួនកាលទូរស័ព្ទទៅទីឆ្ងាយ ដែលលោកអ្នកមិនស្គាល់លេខទូរស័ព្ទនោះ។
- កូនលោកអ្នកទទួល របស់ផ្ញើតាមប៉ុស្តិ៍ អំណោយ ឬ កញ្ចប់របស់ ពីអ្នកណាម្នាក់ដែលលោកអ្នកមិនស្គាល់។
- កូនលោកអ្នកបិទកុំព្យូទ័រ ឬ ប្តូររូបភាពនៅលើកញ្ចក់កុំព្យូទ័រយ៉ាងរហ័ស នៅពេលដែលលោកអ្នកចូលមកក្នុងបន្ទប់។
- កូនលោកអ្នកចាប់ផ្តើមមិនចូលចិត្តធ្វើអ្វីជាមួយក្រុមគ្រួសារ។
- កូនលោកអ្នកប្រើអ៊ិនធ័រណិត ដោយប្រើឈ្មោះរបស់អ្នកដទៃ។